# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ០១៧ គ.ជ.ប. ស.ន.ឈ

# សេចក្ដីជូនដំណឹង

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ទាំង២៥ ត្រូវការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លីចំនួន **៥៥៥ រូប** សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ ដែលមានមុខតំណែងដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- | គ្រូបង្គោល់ | ចំនួន ៤២៤ រូប |
| ២- | ជំនួយការរដ្ឋបាល | ចំនួន ២១ រូប |
| ៣- | ជំនួយការគណនេយ្យ | ចំនួន ២៥ រូប |
| ៤- | ជំនួយការប្រតិបត្តិការ | ចំនួន ២ រូប |
| ៥- | ជំនួយការសេវាកម្មច្បាប់ និងវិវាទកម្ម | ចំនួន ២១ រូប |
| ៦- | លេខាធិការ | ចំនួន ២៥ រូប |
| ៧- | ការីកុំព្យូទ័រ | ចំនួន ២៥ រូប |
| ៨- | អ្នកបើកបររថយន្ត | ចំនួន ១២ រូប |

សាធារណជនដែលមានបំណងដាក់ពាក្យសុំចូលបម្រើការងារតាមមុខតំណែងខាងលើ សូមអញ្ជើញមកទំនាក់ទំនងទទួល និងដាក់ពាក្យសុំប្រឡងចូលបម្រើការងារនៅរៀងរាល់ម៉ោងធ្វើការនៅតាមលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត។

ពាក្យសុំប្រឡងចូលបម្រើការងារនឹងមានចែកជូនដោយឥតគិតថ្លៃ។ បេក្ខជនអាចទាញយកពាក្យសុំប្រឡងចូលបម្រើការងារតាមរយៈអាសយដ្ឋានវេបរបស់ គ.ជ.ប (www.nec.gov.kh) ឬស្កេន QR-Code ដូចមាននៅក្នុងសេចក្ដីជូនដំណឹងនេះ។

- ការចាប់ផ្ដើមចែកពាក្យ និងទទួលពាក្យ ថ្ងៃទី៣ ខែសីហា ឆ្នាំ២០២៦ ( វេលាម៉ោង ៧:០០ នាទីព្រឹក )
- ការឈប់ទទួលពាក្យ ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៦ (វេលាម៉ោង ១៧:៣០ នាទីល្ងាច)។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៦
ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រធាន

ស្កេន QR-Code

ដើម្បីទាញយកពាក្យសុំចូលបម្រើការងារ

ប្រាជ្ញ ចន្ទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ០១៨ គ.ជ.ប.ស.ន.ល

# សេចក្តីជូនដំណឹង
## ស្តីពី
## លក្ខខណ្ឌនៃការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី សម្រាប់បម្រើការងារ នៅតាមលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ត្រូវការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី ចំនួន **៥៥៥** រូប សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ ដែលមានមុខតំណែងដូចខាងក្រោម ៖

| ល.រ | រាជធានី ខេត្ត | គ្រូបង្ហាត់ | លេខាធិការ | ភារី កុំព្យូទ័រ | ជំនួយការ ប្រតិបត្តិការ | អ្នកបើកបរ រថយន្ត | ជំនួយការ រដ្ឋបាល | ជំនួយការ គណនេយ្យ | ជំនួយការ សេវាកម្មច្បាប់ និងវិវាទកម្ម | សរុប |
|---|---|---|---|---|---|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | ១៨ | ១ | ១ | X | ១ | ១ | ១ | ១ | ២៤ |
| ២ | បាត់ដំបង | ៣០ | ១ | ១ | X | X | ១ | ១ | ១ | ៣៥ |
| ៣ | កំពង់ចាម | ២០ | ១ | ១ | X | ១ | ១ | ១ | ១ | ២៦ |
| ៤ | កំពង់ឆ្នាំង | ១៦ | ១ | ១ | X | X | ១ | ១ | ១ | ២១ |
| ៥ | កំពង់ស្ពឺ | ១៨ | ១ | ១ | ១ | X | ១ | ១ | ១ | ២៤ |
| ៦ | កំពង់ធំ | ១៨ | ១ | ១ | X | X | ១ | ១ | ១ | ២៣ |
| ៧ | កំពត | ១៨ | ១ | ១ | X | X | ១ | ១ | ១ | ២៣ |
| ៨ | កណ្តាល | ២៦ | ១ | ១ | X | ១ | X | ១ | ១ | ៣១ |
| ៩ | កោះកុង | ១៤ | ១ | ១ | X | ១ | X | ១ | ១ | ១៩ |
| ១០ | ក្រចេះ | ១៤ | ១ | ១ | X | X | ១ | ១ | ១ | ១៩ |
| ១១ | មណ្ឌលគិរី | ១២ | ១ | ១ | X | X | ១ | ១ | X | ១៦ |
| ១២ | ភ្នំពេញ | ២៨ | ១ | ១ | X | ១ | X | ១ | ១ | ៣៣ |
| ១៣ | ព្រះវិហារ | ១៦ | ១ | ១ | X | ១ | X | ១ | ១ | ២១ |
| ១៤ | ព្រៃវែង | ២៦ | ១ | ១ | X | X | ១ | ១ | ១ | ៣១ |
| ១៥ | ពោធិ៍សាត់ | ១៤ | ១ | ១ | X | X | ១ | ១ | ១ | ១៩ |
| ១៦ | រតនគិរី | ១៨ | ១ | ១ | X | ១ | ១ | ១ | X | ២៣ |
| ១៧ | សៀមរាប | ២៦ | ១ | ១ | X | X | ១ | ១ | ១ | ៣១ |
| ១៨ | ព្រះសីហនុ | ១២ | ១ | ១ | ១ | X | ១ | ១ | ១ | ១៨ |
| ១៩ | ស្ទឹងត្រែង | ១២ | ១ | ១ | X | ១ | ១ | ១ | X | ១៧ |
| ២០ | ស្វាយរៀង | ១៦ | ១ | ១ | X | X | ១ | ១ | ១ | ២១ |
| ២១ | តាកែវ | ២០ | ១ | ១ | X | X | ១ | ១ | ១ | ២៥ |
| ២២ | កែប | ៤ | ១ | ១ | X | ១ | ១ | ១ | ១ | ១០ |
| ២៣ | ប៉ៃលិន | ៤ | ១ | ១ | X | ១ | ១ | ១ | ១ | ១០ |
| ២៤ | ឧត្តរមានជ័យ | ១០ | ១ | ១ | X | ១ | ១ | ១ | ១ | ១៦ |
| ២៥ | ត្បូងឃ្មុំ | ១៤ | ១ | ១ | X | ១ | ១ | ១ | X | ១៩ |
| សរុប | | ៤២៤ | ២៥ | ២៥ | ២ | ១២ | ២១ | ២៥ | ២១ | ៥៥៥ |

I- **លក្ខខណ្ឌទូទៅនៃបេក្ខជន ៖**

- មានសញ្ជាតិខ្មែរ និងមានអាយុតាមការកំណត់ក្នុងលក្ខខណ្ឌដោយឡែក
- មានកិរិយាមារយាទល្អ និងសុចរិតទៀងត្រង់ គោរពច្បាប់ និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងក្រមសីលធម៌មន្ត្រីបោះឆ្នោត
- មានសិទ្ធិបោះឆ្នោតនៅក្នុងរាជធានី ខេត្ត ដែលសាមីខ្លួនបានដាក់ពាក្យជាបេក្ខជន
- មានសុខភាពល្អ
- មានលទ្ធភាពធ្វើដំណើរក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងរាជធានី ខេត្ត ឬក្នុងឃុំ សង្កាត់
- មិនមែនជាមន្ត្រីតុលាការក្នុងក្របខ័ណ្ឌការងារ
- មិនមែនជាព្រះសង្ឃ ឬបព្វជិតសាសនា
- មិនមែនជាអភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- មិនមែនជាមេភូមិ អនុប្រធានភូមិ ឬសមាជិកភូមិ
- មិនមែនជាជនដែលតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ
- បេក្ខជនអាចដាក់ពាក្យបានតែមួយមុខតំណែងគត់ ករណីឃើញថាបានដាក់ពាក្យលើសពីមួយមុខតំណែង ការដាក់ពាក្យនៅមុខតំណែងចុងក្រោយត្រូវសម្រេចយកជាផ្លូវការ
- បេក្ខនារី ឬបេក្ខជន និងបេក្ខនារីដែលជាជនជាតិដើមភាគតិចនៅតំបន់ដែលមានជនជាតិដើមភាគតិចតាមចំនួនសមស្រប និងចំពោះបេក្ខជន និងបេក្ខនារីជាជនមានពិការភាពដែលមានសមត្ថភាព និងកាយសម្បទាសមស្របទៅនឹងមុខតំណែង ត្រូវបានលើកទឹកចិត្ត។

II- **លក្ខខណ្ឌដោយឡែក ៖**

**១- គ្រូបង្ហាត់** (រយៈពេលបម្រើការងារ ១-៩-២០២៦ ដល់ ១៥-១២-២០២៦)

**ក- គ្រូបង្ហាត់ដែលអាចប្រើប្រាស់កុំព្យូទ័រច្បាស់លាស់ (ត្រូវការ ១រូប ក្នុងមួយ ក្រុង ស្រុក ខណ្ឌ)**

- មានអាយុយ៉ាងតិច ២៥ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីគ្រូបឋមសិក្សាឡើងទៅ ឬមានបទពិសោធន៍ពាក់ព័ន្ធការងារបណ្តុះបណ្តាល ចាប់ពី ៣ឆ្នាំ ឬមានបទពិសោធន៍ការងារបោះឆ្នោតពាក់ព័ន្ធការងារបណ្តុះបណ្តាល ៣ដងឡើងទៅ
- ចេះប្រើប្រាស់កុំព្យូទ័រច្បាស់លាស់ និងចេះប្រើប្រាស់ Internet និង Email
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងបីមុខគឺ ១-QCM ក្នុងប្រព័ន្ធកុំព្យូទ័រ ២-ធ្វើតេស្តកុំព្យូទ័រ ៣-សម្ភាសន៍។

**ខ- គ្រូបង្ហាត់ផ្នែកទ្រឹស្តី (ត្រូវការ ១រូប ក្នុងមួយ ក្រុង ស្រុក ខណ្ឌ)**

- មានអាយុយ៉ាងតិច ២៥ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីគ្រូបឋមសិក្សាឡើងទៅ ឬមានបទពិសោធន៍ពាក់ព័ន្ធការងារបណ្តុះបណ្តាល ចាប់ពី៣ឆ្នាំ ឬមានបទពិសោធន៍ការងារបោះឆ្នោតពាក់ព័ន្ធការងារបណ្តុះបណ្តាល ៣ដងឡើងទៅ (អាចប្រើប្រាស់កុំព្យូទ័របានកាន់តែប្រសើរ)
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។

**២- លេខាធិការ** (រយៈពេលបម្រើការងារ ១-៩-២០២៦ ដល់ ៣១-១២-២០២៦)

- មានអាយុយ៉ាងតិច ២១ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្ររងសមស្របនឹងមុខតំណែង ឬបទពិសោធន៍ពាក់ព័ន្ធនឹងការងារលេខាធិការ ចាប់ពី ៣ឆ្នាំឡើងទៅ ឬបទពិសោធន៍ការងារបោះឆ្នោតទាក់ទងនឹងមុខតំណែង ៣ដងឡើងទៅ
- ចេះសរសេររបាយការណ៍ និងកំណត់ហេតុ
- មានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។

៣- **ភារីកុំព្យូទ័រ** (រយៈពេលបម្រើការងារ ១-៩-២០២៦ ដល់ ៣១-១២-២០២៦)

- មានអាយុយ៉ាងតិច ២១ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្ររងសមស្របនឹងមុខតំណែង ឬបទពិសោធន៍ការងារទាក់ទងនឹងការប្រើប្រាស់កុំព្យូទ័រចាប់ពី ៣ឆ្នាំ ឬបទពិសោធន៍ការងារបោះឆ្នោតទាក់ទងនឹងមុខតំណែង ៣ដងឡើងទៅ
- មានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងបីមុខគឺ ១- QCM ក្នុងប្រព័ន្ធកុំព្យូទ័រ ២-ធ្វើតេស្តកុំព្យូទ័រ ៣-សម្ភាសន៍។

៤- **ជំនួយការប្រតិបត្តិការ** (រយៈពេលបម្រើការងារ ១-៩-២០២៦ ដល់ ៣១-១២-២០២៦)

- មានអាយុយ៉ាងតិច ២៥ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្ររងសមស្របនឹងមុខតំណែង ឬមានបទពិសោធន៍ការងារប្រតិបត្តិការចាប់ពី ៣ឆ្នាំ ឬមានបទពិសោធន៍ការងារបោះឆ្នោតផ្នែកប្រតិបត្តិការ ៣ដងឡើងទៅ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។

៥- **អ្នកបើកបររថយន្ត** (រយៈពេលបម្រើការងារ ១-៩-២០២៦ ដល់ ៣១-១២-២០២៦)

- មានអាយុយ៉ាងតិច ២២ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានបណ្ណបើកបររថយន្ត
- មានបទពិសោធន៍ក្នុងការងារបើកបរចាប់ពី ២ឆ្នាំឡើងទៅ
- ចេះអាន ចេះសរសេរអក្សរខ្មែរ និងមានអ្នកធានាទទួលស្គាល់គួរជាទីទុកចិត្តបាន
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៣០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងមួយមុខគឺសម្ភាសន៍។

៦- **ជំនួយការរដ្ឋបាល** (រយៈពេលបម្រើការងារ ១-១០-២០២៦ ដល់ ៣១-១-២០២៧)

- មានអាយុយ៉ាងតិច ២៥ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្ររងសមស្របនឹងមុខតំណែង ឬបទពិសោធន៍ការងារទាក់ទងនឹងការងាររដ្ឋបាលចាប់ពី ៣ឆ្នាំ ឬបទពិសោធន៍ការងារបោះឆ្នោតទាក់ទងនឹងការងាររដ្ឋបាល ៣ដងឡើងទៅ
- ចេះសរសេររបាយការណ៍ និងកំណត់ហេតុ
- មានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។

៧- **ជំនួយការគណនេយ្យ** (រយៈពេលបម្រើការងារ ១-១០-២០២៦ ដល់ ៣១-១-២០២៧)

- មានអាយុយ៉ាងតិច ២៥ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្ររងសមស្របនឹងមុខតំណែង ឬបទពិសោធន៍ការងារគណនេយ្យ និងហិរញ្ញវត្ថុចាប់ពី ៣ឆ្នាំ ឬបទពិសោធន៍ការងារបោះឆ្នោតទាក់ទងនឹងគណនេយ្យ និងហិរញ្ញវត្ថុ ៣ដងឡើងទៅ ព្រមទាំងមានអ្នកធានាទទួលស្គាល់គួរជាទីទុកចិត្តបាន
- មានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។

៨- **ជំនួយការសេវាកម្មច្បាប់ និងវិវាទកម្ម** (រយៈពេលបម្រើការងារ ១-១០-២០២៦ ដល់ ៣១-១-២០២៧)

- មានអាយុយ៉ាងតិច ២៥ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្ររងសមស្របនឹងមុខតំណែង ឬបទពិសោធន៍ការងារច្បាប់ចាប់ពី ៣ឆ្នាំ ឬបទពិសោធន៍ការងារបោះឆ្នោតទាក់ទងនឹងវិស័យច្បាប់ ៣ដងឡើងទៅ
- មានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។

III- **ទំនាក់ទំនងព័ត៌មាន**

សាធារណជនដែលមានបំណងដាក់ពាក្យជាបេក្ខជនតាមមុខតំណែងខាងលើនេះ សូមអញ្ជើញមកទំនាក់ទំនងទទួល និងដាក់ពាក្យសុំប្រឡងចូលបម្រើការងារនៅរៀងរាល់ម៉ោងធ្វើការនៅតាមលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត។

ពាក្យសុំប្រឡងចូលបម្រើការងារនឹងមានចែកជូនដោយឥតគិតថ្លៃ។ បេក្ខជនអាចទាញយកពាក្យសុំប្រឡងចូលបម្រើការងារតាមគេហទំព័ររបស់ គ.ជ.ប (www.nec.gov.kh) ឬស្កេន QR-Code លើសេចក្តីជូនដំណឹងផ្សព្វផ្សាយ។

IV- **កាលបរិច្ឆេទនៃការចែកពាក្យ ទទួលពាក្យ ការបិទផ្សាយបញ្ជីឈ្មោះបេក្ខជនប្រឡង និងការប្រឡង**

- ការចាប់ផ្តើមចែកពាក្យ និងទទួលពាក្យ ថ្ងៃទី៣ ខែសីហា ឆ្នាំ២០២៦ (វេលាម៉ោង ៧:០០ នាទីព្រឹក)
- ការឈប់ទទួលពាក្យ ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៦ (វេលាម៉ោង ១៧:៣០ នាទីល្ងាច)
- រាជធានី និងខេត្តក្រុមទី១ ត្រូវធ្វើការពិនិត្យពាក្យ និងសម្រាំងបេក្ខជន និងបិទផ្សាយបញ្ជីឈ្មោះប្រឡងនៅថ្ងៃទី១០-១១ ខែសីហា ឆ្នាំ២០២៦ នឹងប្រឡងនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៦ រួមមាន រាជធានីភ្នំពេញ ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តតាកែវ ខេត្តកំពង់ស្ពឺ ខេត្តព្រៃវែង ខេត្តកែប ខេត្តមណ្ឌលគិរី ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ
- ខេត្តក្រុមទី២ ត្រូវធ្វើការពិនិត្យពាក្យ និងសម្រាំងបេក្ខជន និងបិទផ្សាយបញ្ជីឈ្មោះប្រឡងនៅថ្ងៃទី១២-១៣ ខែសីហា ឆ្នាំ២០២៦ នឹងប្រឡងនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៦ រួមមាន ខេត្តកណ្តាល ខេត្តសៀមរាប ខេត្តពោធិ៍សាត់ ខេត្តស្ទឹងត្រែង ខេត្តត្បូងឃ្មុំ ខេត្តកំពត ខេត្តកោះកុង ខេត្តស្វាយរៀង ខេត្តព្រះសីហនុ ខេត្តរតនគិរី ខេត្តប៉ៃលិន ខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ។

V- **ការអនុវត្តតាមបទបញ្ជាផ្ទៃក្នុងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

អនុគណៈកម្មការរៀបចំការប្រឡង ត្រូវពិនិត្យសំណុំលិខិតរបស់បេក្ខជនដោយត្រូវធ្វើការពិនិត្យ និងជ្រើសរើសយកបេក្ខជនណាដែលមានលក្ខខណ្ឌល្អជាងគេមកប្រឡង និងសម្ភាសន៍។ សំណុំលិខិតរបស់បេក្ខជនមិនត្រូវបានប្រគល់ជូនវិញទេ។

VI- **លទ្ធផលនៃការប្រឡង និងសម្ភាសន៍**

លទ្ធផលនៃការប្រឡង និងសម្ភាសន៍នឹងបិទផ្សាយនៅតាមលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត។

**<u>បញ្ជាក់បន្ថែម</u> ៖**

- សញ្ញាបត្រ ឬ/និងលិខិតបញ្ជាក់ពីបទពិសោធន៍ការងារត្រូវធ្វើនីត្យានុកូលកម្ម ឬមានការបញ្ជាក់ពីសាមីស្ថាប័ន
- គ្រប់បេក្ខជនត្រូវមានអ្នកធានាដឹងឮយ៉ាងតិចមួយនាក់
- បេក្ខជនទាំងអស់ត្រូវធានាថា ក្រោយពីពេលដែលត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារក្នុងមុខតំណែងណាមួយនោះ ត្រូវសុខចិត្តទទួលយកប្រាក់កម្រៃដូចបានកំណត់ហើយនឹងត្រូវបើកជូនក្រោយពី គ.ជ.ប បានទទួលប្រាក់ពីរតនាគារជាតិ
- យោងតាមមាត្រា២៦ នៃអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចែងថា «... មន្ត្រីរាជការ ដែលត្រូវបានជ្រើសរើសពីក្រសួង ស្ថាប័ននានា ជាមន្ត្រីជាប់កិច្ចសន្យាបម្រើការងារឱ្យ គ.ជ.ប ត្រូវបានរក្សាបៀវត្ស ប្រាក់បំណាច់ផ្សេងៗ អតីតភាពការងារ សម្រាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍នៅអង្គភាពដើមរបស់ខ្លួនដដែល »
- ការសូក និងទទួលសំណូកគឺជាអំពើខុសច្បាប់ ដែលត្រូវផ្តន្ទាទោសតាមច្បាប់។

ថ្ងៃព្រហស្បតិ៍ ៩ រោច ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០២៦

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**